# ទស្សនាទានស្តីពីក្របខណ្ឌការងារគម្រោង

# "ការបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ"

# នៅសាលារៀនមធ្យមសិក្សា និងឧត្តមសិក្សាថ្នាក់ឆ្នាំមូលដ្ឋាន

# តាមរយៈក្រសួងអប់រំ យុវជន និង កីឡា

# ដោយសហការជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា

# ឆ្នាំ២០១១-២០១៣

**ទស្សនាទានស្តីពីក្របខណ្ឌការងារគម្រោង**

**"ការបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ"**

**នៅសាលារៀនមធ្យមសិក្សា និងឧត្តមសិក្សាថ្នាក់ឆ្នាំមូលដ្ឋាន**

**តាមរយៈក្រសួងអប់រំ យុវជន និង កីឡា ដោយសហការជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា**

**ឆ្នាំ២០១១-២០១៣**

## ក. ការពណ៌នាអំពីគម្រោង

- ឈ្មោះគម្រោងគឺការបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យនៅសាលារៀនមធ្យមសិក្សា និងឧត្តមសិក្សាថ្នាក់ឆ្នាំមូលដ្ឋាន
- ស្ថាប័នអនុវត្តន៍គឺក្រសួងអប់រំ យុវជន និង កីឡា
- ជំនួយបច្ចេកទេស និងថវិកាពីមជ្ឈមណ្ឌលឯកសារកម្ពុជា
- រយៈពេលនៃគម្រោងគឺ ២០១១ ដល់ ២០១៣
- គោលដៅនៃគម្រោងគឺគ្រូបង្រៀនចំនួន ១,៦០០នាក់ សម្រាប់រយៈពេល៣ឆ្នាំ គឺពីឆ្នាំ២០១១ ដល់ឆ្នាំ២០១៣ នឹងទទួលបានការបំប៉នឱ្យយល់ដឹង និងចេះវិធីបង្រៀនប្រវត្តិសាស្ត្រ កម្ពុជាប្រជាធិបតេយ្យ។ រយៈកាលកន្លងមកគិតពីឆ្នាំ២០០៨ ដល់ឆ្នាំ២០១០ កម្មវិធីនេះបាន បំប៉នគ្រូបង្រៀនចំនួន ១០៥៧ នាក់រួចមកហើយ។
- បន្ថែមពីលើនេះ គម្រោងនឹងផ្តល់វគ្គបណ្តុះបណ្តាលសម្រាប់បំប៉នគ្រូបង្រៀនថ្នាក់ឆ្នាំមូលដ្ឋាននៅគ្រឹះស្ថានឧត្តមសិក្សាចំនួន ២០០ នាក់ក្នុងរយៈពេលនៃគម្រោង
- គោលបំណងនៃកិច្ចសហការគឺផ្តល់វិធីសាស្ត្រជឿនលឿន និងមានប្រសិទ្ធភាពក្នុងការបង្រៀន និងរៀនប្រវត្តិសាស្ត្រនៃរបបកម្ពុជាប្រជាធិបតេយ្យដល់គ្រូបង្រៀន និងសិស្សានុសិស្សនៅកម្រិតមធ្យមសិក្សា និងឧត្តមសិក្សាថ្នាក់ឆ្នាំមូលដ្ឋាន។ ការចាប់ផ្តើមគឺនៅឆ្នាំ២០១១ ហើយបញ្ចប់នៅឆ្នាំ២០១៣។

### ១. ការកសាងឯកសារ និង ការកសាងសមត្ថភាព

- សៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យដែលនិពន្ធដោយលោក ឌី ខាំបូលី ហើយបោះពុម្ពផ្សាយដោយមជ្ឈមណ្ឌលឯកសារកម្ពុជា គឺជាឯកសារយោងសម្រាប់ប្រើជាគោលក្នុងវគ្គបណ្តុះបណ្តាលគ្រូ និងប្រើប្រាស់ក្នុងការតាក់តែង

កិច្ចតែងការបង្រៀនសម្រាប់បំពេញខ្លឹមសារមេរៀន ឬ បញ្ជ្រាបខ្លឹមសារអំពើប្រល័យពូជសាសន៍ខ្មែរក្រហមនៅកម្ពុជា ក្នុងកម្មវិធីសិក្សារបស់សាលារៀន។

- ការកសាងសៀវភៅណែនាំគ្រូអំពីការបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ត្រូវបានរៀបចំឡើងដោយក្រសួងអប់រំ យុវជន និង កីឡា សហការជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា។

- ការរៀបចំវគ្គបណ្តុះបណ្តាលគ្រូប្រវត្តិវិទ្យានៅមធ្យមសិក្សាចំនួន ៥៤០ នាក់ សម្រាប់ឆ្នាំ២០១១។ ចំពោះគ្រូបង្រៀនមុខវិជ្ជាអក្សរសាស្ត្រខ្មែរ និងសីលធម៌-ពលរដ្ឋ មជ្ឈមណ្ឌលឯកសារកម្ពុជានឹងរៀបចំបណ្តុះបណ្តាលជាបន្តបន្ទាប់ក្រោយមកទៀត។

- ការរៀបចំប្រជុំប្រចាំឆ្នាំរៀងរាល់ឆ្នាំជាមួយលោកគ្រូអ្នកគ្រូថ្នាក់ជាតិ និងឧទ្ទេសថ្នាក់ខេត្ត។ ការប្រជុំនេះនឹងជួយពង្រឹងសមត្ថភាពរបស់លោកគ្រូអ្នកគ្រូក្នុងការស្រាវជ្រាវ និងចងក្រងប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យឱ្យកាន់តែប្រសើរឡើង។

- ការរៀបចំតាមដានអង្កេតគុណភាពបង្រៀនលើមុខវិជ្ជាប្រវត្តិសាស្ត្រស្តីអំពីរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)។

- ការរៀបចំផ្សព្វផ្សាយពាក្យស្លោកនៅតាមវិទ្យាល័យទាំងអស់នៅទូទាំងប្រទេស ស្តីពី "និយាយពីការរស់នៅក្នុងសម័យខ្មែរក្រហមគឺនិយាយពីការផ្សះផ្សា អប់រំកូនចៅឱ្យអត់ឱន អធ្យាស្រ័យគ្នា" និង "រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យគឺរៀនពីការទប់ស្កាត់អំពើប្រល័យពូជសាសន៍"។

- ការរៀបចំចែកចាយ "សៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)" ដល់សិស្សានុសិស្សនៅទូទាំងព្រះរាជាណាចក្រកម្ពុជា។

- ការរៀបចំបណ្តុះបណ្តាលអំពីវិធីសាស្ត្រក្នុងការបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ដល់គ្រូឧត្តមសិក្សាថ្នាក់ឆ្នាំមូលដ្ឋានទូទាំងប្រទេស។

- ការរៀបចំបកប្រែសៀវភៅប្រវត្តិសាស្ត្រ ដែលសរសេរឡើងដោយអ្នកនិពន្ធខ្មែរទៅជាភាសាអង់គ្លេសសម្រាប់អ្នកអានអន្តរជាតិ។ ជំហានដំបូងគឺនឹងបកប្រែសំណេរ "ប្រវត្តិសាស្ត្រភូមិយើង" ដែលសរសេរឡើងដោយលោកគ្រូអ្នកគ្រូបង្គោលថ្នាក់ជាតិ និងឧទ្ទេសថ្នាក់ខេត្តទាំងអស់។

**២. ការសង្កេតតាមដាន និង ការពង្រឹងការបង្រៀននៅតាមសាលារៀន**

- ការសង្កេតតាមដាន និង ការបង្រៀនគ្រូបង្រៀននឹងធ្វើនៅក្នុងអំឡុងឆ្នាំសិក្សា២០១១-២០១៣។ លទ្ធផលនៃការសង្កេតនឹងត្រូវបានប្រមូលចងក្រងជាអនុសាសន៍ ដើម្បីកែលម្អសៀវភៅណែនាំគ្រូឱ្យកាន់តែមានប្រសិទ្ធភាព ហើយនឹងប្រើប្រាស់សម្រាប់ការពិនិត្យឡើងវិញនូវកម្មវិធីសិក្សា និង ការអភិវឌ្ឍការបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យឱ្យកាន់តែប្រសើរឡើង។

## ខ. លក្ខខណ្ឌទូទៅ

- មជ្ឈមណ្ឌលឯកសារកម្ពុជាគាំទ្រគោលនយោបាយអប់រំរបស់ក្រសួងអប់រំ យុវជន និង កីឡា និងគោរពតាមបែបបទរដ្ឋបាលរបស់ក្រសួង។
- មជ្ឈមណ្ឌលឯកសារកម្ពុជាធ្វើកិច្ចសហការយ៉ាងជិតស្និទ្ធជាមួយក្រសួងអប់រំ ដើម្បីពង្រីក និងផ្ទេរជំនាញ និង ពង្រឹងជំនាញ សមត្ថភាពរបស់មន្ត្រីឯកទេសរបស់ក្រសួងអប់រំ យុវជន និង កីឡា ឱ្យកាន់តែប្រសើរឡើង។
- ការផ្សាយចេញនូវរបាយការណ៍ ឬ អត្ថបទដែលកើតបានមកពីកិច្ចសហការរវាងមជ្ឈមណ្ឌលឯកសារកម្ពុជា និងក្រសួងអប់រំ យុវជន និង កីឡា ត្រូវមានការទទួលស្គាល់ ឬ ការឯកភាពពីក្រសួងអប់រំ យុវជន និង កីឡា។
- ក្រសួងអប់រំ យុវជន និង កីឡានឹងសម្របសម្រួលការផ្តល់ទីកន្លែងសម្រាប់ធ្វើសិក្ខាសាលា ឬបើកវគ្គបណ្តុះបណ្តាលគ្រូបង្រៀនមុខវិជ្ជាប្រវត្តិសាស្ត្រ សីលធម៌-ពលរដ្ឋវិជ្ជា អក្សរសាស្ត្រ និង ផ្តល់ទិដ្ឋាការសមស្របនិងតាមសេចក្តីត្រូវការសម្រាប់មន្ត្រី និងបុគ្គលិកពាក់ព័ន្ធនឹងការងារដូចបានរៀបរាប់ក្នុង **ចំណុច ក** ដើម្បីចុះអនុវត្តការងារតាមគោលដៅដែលបានឯកភាពរួចហើយ។
- ក្រសួងអប់រំ យុវជន និង កីឡា នឹងជួយសម្រួលដល់មជ្ឈមណ្ឌលឯកសារកម្ពុជាក្នុងការចែកចាយសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យចំនួន ២០០,០០០ក្បាល (ម្ភៃម៉ឺនក្បាល) ទៅដល់គ្រប់អនុវិទ្យាល័យ និងវិទ្យាល័យទាំងអស់នៅទូទាំងព្រះរាជាណាចក្រកម្ពុជា។ រយៈកាលកន្លងមក មជ្ឈមណ្ឌលឯកសារកម្ពុជាបានចែកចាយសៀវភៅប្រវត្តិសាស្ត្រនេះចំនួន ៣០០.០០០ (សាមសិបម៉ឺន) ក្បាលរួចមកហើយ។
- ក្រសួងអប់រំ យុវជន និង កីឡា មានសិទ្ធិក្នុងការបញ្ចប់សកម្មភាពរបស់គម្រោង និងកិច្ចសហការក្នុងករណីពិនិត្យឃើញថា មជ្ឈមណ្ឌលឯកសារកម្ពុជាមានទំនោរបម្រើមនោគមវិជ្ជា ឬផលប្រយោជន៍របស់បក្សនយោបាយណាមួយ ឬបង្កឱ្យមានការប្រទូសរ៉ាយណាដែលប្រឈមនឹងច្បាប់របស់រដ្ឋ។

- ក្រសួងអប់រំ យុវជន និង កីឡា និងមជ្ឈមណ្ឌលឯកសារកម្ពុជា ធ្វើការត្រួតពិនិត្យមើលលើការរីកចម្រើន និងប្រសិទ្ធភាពនៃការអនុវត្តនៅមុនរយៈពេលបីខែដែលគម្រោងនឹងត្រូវបញ្ចប់ ដើម្បីធ្វើការសម្រេចចិត្តបញ្ចប់គម្រោង ឬស្វែងរកការបន្តគម្រោងតទៅទៀត។

គោលបំណងនៃទស្សនាទានស្តីពីក្របខណ្ឌការងារគម្រោង "ការបង្រៀនអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ" នៅសាលារៀនមធ្យមសិក្សា គឺផ្តល់នូវក្របខណ្ឌការងារដែលគ្របដណ្តប់លើកិច្ចសហការរវាងក្រសួងអប់រំ យុវជន និង កីឡា និងមជ្ឈមណ្ឌលឯកសារកម្ពុជា រយៈពេល៣ឆ្នាំ ដោយធានានូវភាពជាក់លាក់ និងជំនឿទុកចិត្តមួយមុននឹងឈានទៅធ្វើការអនុវត្តសកម្មភាព។ ទស្សនាទានស្តីពីក្របខណ្ឌការងារគម្រោងនេះ មិនមែនជាកាតព្វកិច្ចកំណត់ដោយច្បាប់ទេ ប៉ុន្តែវាជាកិច្ចសន្យារួមមួយដែលមានចែងពីការទទួលខុសត្រូវរបស់ភាគីក្រសួង និងមជ្ឈមណ្ឌលឯកសារកម្ពុជា។

ឯកសារទស្សនាទានស្តីពីក្របខណ្ឌការងារគម្រោង "ការបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ" នៅសាលារៀនមធ្យមសិក្សាត្រូវបានធ្វើឡើងជាភាសាខ្មែរ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី...២២... ខែ...៥....... ឆ្នាំ២០១០

**តំណាងក្រសួងអប់រំ យុវជន និង កីឡា**

**ជ. រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា**

**រដ្ឋលេខាធិការ**

**ធន់ សារ៉ុម**

**តំណាងមជ្ឈមណ្ឌលឯកសារកម្ពុជា**

**នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា**